**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**រដ្ឋបាលជលផល**

# សេចក្តីប្រកាសព័ត៌មាន

រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសង្កេតឃើញថា ថ្មីៗនេះមានការផ្សព្វផ្សាយ និងចែករំលែកក្នុងបណ្តាញសង្គមយ៉ាងផុសផុល អំពីការប្រទះឃើញផ្សោតឬត្រីដូហ្វីនពណ៌ផ្កាឈូក នៅសមុទ្រកម្ពុជា ត្រង់ចំណុចពាក់កណ្តាលផ្លូវកំពង់សោម និងកោះរ៉ុង ដោយភ្ជាប់នូវរូបភាពសត្វផ្សោតឃ្លៀច (ផ្សោតពណ៌ផ្កាឈូក) ដែលមានប្រភពមិនច្បាស់លាស់។ ករណីនេះរដ្ឋបាលជលផលសូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា នៅក្នុងសមុទ្រកម្ពុជាមានផ្សោតឃ្លៀចឬផ្សោតផ្កាឈូក (Indo-Pacific humpbacked dolphin - *Sousa chinensis*) ដែលហែលជាហ្វូងជាមួយប្រភេទផ្សោតសមុទ្រដទៃទៀត។ ហ្វូងផ្សោតទាំងនោះតែងតែមានវត្តមានក្នុងសមុទ្រនៃខេត្តកែប កំពត ប្រជុំកោះរ៉ុង នៃខេត្តព្រះសីហនុ និងខាងមុខពាមក្រសោបនៃខេត្តកោះកុង។

រដ្ឋបាលជលផលសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ នូវការចូលរួមផ្សព្វផ្សាយអំពីធនធានជលផលសមុទ្រដ៏មានតម្លៃរបស់យើង ដើម្បីទាក់ទាញទេសចរណ៍មកកំសាន្តឱ្យកាន់តែច្រើន។ ប៉ុន្តែរដ្ឋបាលជលផលស្នើសុំបងប្អូនដែលប្រើប្រាស់បណ្តាញសង្គមដើម្បីផ្សព្វផ្សាយ ត្រូវប្រើប្រាស់ព័ត៌មាននិងរូបភាពជាក់ស្តែងក្នុងសមុទ្រយើងផ្ទាល់ កុំប្រើប្រាស់រូបភាពមិនមានប្រភពច្បាស់លាស់ រូបភាពពីក្រៅប្រទេស ឬរូបភាពកែច្នៃ ដូចករណីផ្សោតឃ្លៀចដែលបាននិងកំពុងចែកចាយតៗគ្នានេះ។ ការប្រើរូបភាពដែលមានប្រភពពីក្រៅប្រទេសឬមិនច្បាស់លាស់ នាំឱ្យមានការភ័ន្តច្រឡំ ដូចនេះសូមអ្នកផ្សព្វផ្សាយនិងចែករំលែក មេត្តាលុបចេញ។

រដ្ឋបាលជលផលសូមលើកទឹកចិត្តដល់បងប្អូនប្រជាពលរដ្ឋ ចូលរួមថែរក្សាការពារធនធានជលផលរបស់យើងទាំងអស់គ្នា និងសូមផ្តល់ព័ត៌មាននូវការប្រទះឃើញនូវធនធានជលផលដ៏កម្រនិងមានតម្លៃ ដល់សមត្ថកិច្ចជំនាញជលផល ដែលមានលេខទូរសព្ទ ០៩៧ ៦៦៦ ៤៩៩៩ / ០១១ ៣៥៥ ៨៨៣ / ០៨៨ ៨៣៥៥ ៨៨៣ /០១២ ៨៩៧ ៩៤៣។

ថ្ងៃសៅរ៍ ១រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៤










អាសយដ្ឋាន:អាគារលេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ៥៨២ /Fax: (855) 23 215 470 www.fia.gov.kh
Address #186 Preah Norodom Blvd., Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh capital, Cambodia. P.O.Box 582 /Fax: (855) 23 215 470 www.fia.gov.kh